ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...០៥...សរ.ណន

# សារាចរណែនាំ

## ស្ដីពី

## វិធានការចាំបាច់នានាក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ

រាជរដ្ឋាភិបាលបាន និងកំពុងធ្វើកំណែទម្រង់ស៊ីជម្រៅលើការគ្រប់គ្រងធនធានធម្មជាតិ ជាពិសេសទៅលើវិស័យព្រៃឈើ និងជលផល តាមរយៈការជំរុញឱ្យមានការធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក៏ដូចជាការបែងចែកឡើងវិញនូវសមត្ថកិច្ចឱ្យបានច្បាស់លាស់រវាងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ ព្រមទាំងរវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានានូវការលើកកម្ពស់ប្រសិទ្ធភាព និងនិរន្តរភាពនៃការគ្រប់គ្រងធនធានធម្មជាតិ។

ជាមួយគ្នានេះដែរ នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានសម្រេចផ្ទេរ និងប្រគល់សមត្ថកិច្ចគ្រប់គ្រងតំបន់ការពារ និងអភិរក្សព្រៃឈើទាំងអស់ទៅឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន និងសមត្ថកិច្ចគ្រប់គ្រងតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ចទាំងអស់ ទៅឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងបានដាក់បញ្ចូលតំបន់ព្រៃឈើមួយចំនួនបន្ថែមទៀតឱ្យក្លាយទៅជាតំបន់ការពារធម្មជាតិ។

ស្របពេលនឹងការផ្ទេរសមត្ថកិច្ចគ្រប់គ្រងតំបន់ទាំងនេះ និងការជំរុញឱ្យមានការធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា បុគ្គលមួយចំនួនបាន និងកំពុងឆ្លៀតឱកាសប្រព្រឹត្តបទល្មើសធនធានធម្មជាតិដ៏គួរឱ្យព្រួយបារម្ភនៅក្នុងតំបន់ការពារ និងអភិរក្សធម្មជាតិ។ ដើម្បីធានាបានប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងដំណាក់កាលនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការចាំបាច់នានា ដូចខាងក្រោម៖

១. អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមរយៈគណៈបញ្ជាការឯកភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវដឹកនាំ សម្របសម្រួលកម្លាំងអធិការ ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលព្រៃឈើ អធិការ ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលជលផល មន្ទីរបរិស្ថាន និងកងកម្លាំងមានសមត្ថកិច្ចនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យអនុវត្តឱ្យបានត្រឹមត្រូវនូវតួនាទីភារកិច្ចរបស់ខ្លួនសំដៅពង្រឹងសមត្ថកិច្ច និងការទទួលខុសត្រូវរបស់គណៈបញ្ជាការឯកភាពគ្រប់ថ្នាក់ចំពោះរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង ការថែរក្សា និងការ

ការពារធនធានធម្មជាតិ ដោយត្រូវចាត់វិធានការឱ្យបានហ្មត់ចត់ក្នុងការទប់ស្កាត់ ការបង្ក្រាប និងការលុបបំបាត់បទល្មើសធនធានធម្មជាតិគ្រប់ប្រភេទ រួមទាំងការរុករានដីនៅក្នុងតំបន់ការពារ និងអភិរក្សធម្មជាតិដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

២. អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបង្កលទ្ធភាព និងលើកទឹកចិត្តឱ្យសហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាចូលរួមទប់ស្កាត់ និងលុបបំបាត់បទល្មើសធនធានធម្មជាតិគ្រប់ប្រភេទនៅក្នុងតំបន់ការពារ និងអភិរក្សធម្មជាតិដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗត្រូវរៀបចំកិច្ចប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងអង្គការសង្គមស៊ីវិល អង្គការសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធនានាឱ្យបានយ៉ាងតិចម្តងក្នុងមួយត្រីមាស ឬអាចកោះប្រជុំតាមការចាំបាច់ ដើម្បីពិនិត្យពិភាក្សាអំពីស្ថានភាពនៃការគ្រប់គ្រងធនធានធម្មជាតិ និងដើម្បីចាត់វិធានការដាក់ស្តែងនានាក្នុងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

៣. ប្រគល់សមត្ថកិច្ចដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការឱ្យបានម៉ឺងម៉ាត់ និងហ្មត់ចត់ ដូចខាងក្រោម៖

- គ្រប់គ្រងរាល់សិប្បកម្មកែច្នៃ និងអាជីវកម្មធនធានព្រៃឈើ និងជលផលដែលមានច្បាប់អនុញ្ញាត ព្រមទាំងទប់ស្កាត់ និងលុបបំបាត់សិប្បកម្មកែច្នៃ និងអាជីវកម្មធនធានព្រៃឈើ និងជលផលដែលគ្មានច្បាប់អនុញ្ញាត
- ត្រួតពិនិត្យ និងចាត់វិធានការលុបបំបាត់ការដឹកជញ្ជូន និងការស្តុកឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃពីឈើគ្រប់ប្រភេទព្រមទាំងសត្វព្រៃដែលគ្មានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ ទៅក្រៅប្រទេសតាមច្រកព្រំដែន និងតាមច្រករបៀង
- ដឹកនាំ សម្របសម្រួលអធិការ ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលព្រៃឈើ អធិការ ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលជលផល មន្ទីរបរិស្ថាន និងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធទាំងឡាយ ដើម្បីធានាបាននូវការប្រើប្រាស់កម្លាំងសរុប និងមធ្យោបាយចាំបាច់នានាក្នុងការថែរក្សា និងការពារធនធានធម្មជាតិព្រមទាំងទប់ស្កាត់ និងបង្ក្រាបសកម្មភាពបទល្មើសនៅក្នុងតំបន់ការពារ និងអភិរក្សធម្មជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើរបាយការណ៍បូកសរុបប្រចាំត្រីមាស ឬធ្វើរបាយការណ៍ក្នុងករណីចាំបាច់ អំពីស្ថានភាពនៃការគ្រប់គ្រងតំបន់ការពារ និងអភិរក្សធម្មជាតិនានាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជូនក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវចម្លងជូនក្រសួងមហាផ្ទៃ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស។ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើការបូកសរុបរបាយការណ៍ទាំងនេះ ដើម្បីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល។

៤. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានរដ្ឋបាលព្រៃឈើជាសេនាធិការត្រូវត្រួតពិនិត្យ និងពង្រឹងការគ្រប់គ្រងឱ្យបានម៉ឺងម៉ាត់នូវការចេញលិខិតអនុញ្ញាតដឹកជញ្ជូនផល និងអនុផលព្រៃឈើគ្រប់ប្រភេទ ដើម្បីទប់ស្កាត់ និងលុបបំបាត់ការដឹកជញ្ជូនផល និងអនុផលព្រៃឈើខុសច្បាប់។

៥. ក្រសួងបរិស្ថាន ដោយមានអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិជាសេនាធិការ ត្រូវពង្រឹងយន្តការ និងផ្តល់កម្លាំងគាំទ្រដល់គណៈបញ្ជាឯកភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

៦. រាល់អន្តរាគមន៍របស់អង្គភាព ឬបុគ្គលដែលគ្មានសមត្ថកិច្ចលើការដឹកជញ្ជូនផល និងអនុផលព្រៃឈើ ត្រូវបានហាមឃាត់ជាដាច់ខាត ហើយនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

៧. ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវផ្តល់កិច្ចសហការ និងគាំទ្រដល់គណៈបញ្ជាការឯកភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តវិធានការទាំងនេះ។

៨. ក្នុងករណីចាំបាច់ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត អាចស្នើសុំកម្លាំងអន្តរាគមន៍ជាបន្ទាន់មកមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

៩. រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការងារគ្រប់គ្រងធនធានធម្មជាតិរៀងរាល់ត្រីមាស។

គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តសារាចរណែនាំនេះឱ្យបានម៉ឺងម៉ាត់បំផុត និងមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន*
- *គ្រប់សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*